ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ..១២៩៥៩......អពដ

ថ្ងៃសុក្រ ១៣ រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០២១

# សេចក្តីណែនាំ

## ស្តីពី

## ការទទួលស្គាល់ចំណូល និងចំណាយចំពោះសហគ្រាសប្រកបអាជីវកម្មដាំដំណាំកៅស៊ូ

អនុលោមតាមកថាខណ្ឌ៤ ប្រការ ៣៦ និងកថាខណ្ឌ៤ ប្រការ ៣៨ នៃប្រកាសលេខ ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីពន្ធលើប្រាក់ចំណូល និងដើម្បីឱ្យមានសង្គតិភាពក្នុងការអនុវត្ត អគ្គនាយកដ្ឋានពន្ធដារ សូមធ្វើការណែនាំចំពោះអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស *ដែលប្រកបអាជីវកម្មដាំដំណាំកៅស៊ូ* ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលស្គាល់ចំណូល និងចំណាយសម្រាប់គោលដៅពន្ធលើប្រាក់ចំណូលដូចខាងក្រោម៖

### ១. ការទទួលស្គាល់ចំណូលជាប់ពន្ធ

សហគ្រាសត្រូវទទួលស្គាល់ចំណូលជាប់ពន្ធនៅពេលផ្គត់ផ្គង់ទំនិញឬសេវា។ ពេលផ្គត់ផ្គង់ទំនិញឬសេវា គឺពេលដែល សហគ្រាសបានចេញវិក្កយបត្រ ប្រសិនបើវិក្កយបត្របានចេញមុនពេលបញ្ជូនទំនិញឬទទួលប្រាក់ ឬពេលបញ្ជូនទំនិញឬការបំពេញសេវា ឬពេលទូទាត់ប្រាក់។ ចំណូលពីការផ្គត់ផ្គង់ទំនិញឬសេវាទាំងនោះរួមមាន៖

ក) ចំណូលពីការផ្គត់ផ្គង់ផលិតផល៖ ជ័រកៅស៊ូទឹកឬកៅស៊ូបង្កក កៅស៊ូក្រែប

ខ) ចំណូលពីសកម្មភាពអាជីវកម្មបន្ទាប់បន្សំ៖ កូនកៅស៊ូ ដើមកៅស៊ូ សេវាឈូសឆាយដី...

គ) ចំណូលផ្សេងៗ៖ ចំណូលពីមូលបត្រ ភាគហ៊ុន ចំណូលហិរញ្ញវត្ថុ...

### ២. ចំណាយដែលត្រូវបញ្ចូលក្នុងថ្លៃដើមកៅស៊ូ

សហគ្រាសត្រូវទទួលស្គាល់ចំណាយតាមគោលការណ៍ដូចខាងក្រោម៖

២.១. រាល់ចំណាយក្នុងដំណាក់កាលដាំដុះដំបូង គិតចាប់ពីការបណ្តុះពូជរហូតដល់ពេលដែលចាប់ផ្តើមប្រមូលផលឬចៀរជ័រ ដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការដាំដុះដំណាំកៅស៊ូ ត្រូវបានបញ្ចូលក្នុងថ្លៃដើមដំណាំកៅស៊ូ។ ចំណាយទាំងនោះមានជាអាទិ៍៖

ក. ការឈូសឆាយដី និងការរៀបចំដីដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការដាំដំណាំកៅស៊ូ

ខ. ការដាំដំណាំកៅស៊ូរួមមាន៖ ការទិញកូនកៅស៊ូ ឬការបណ្តុះកូនកៅស៊ូ និងថ្លៃពលកម្មក្នុងការដាំដុះ

គ. ចំណាយលើហេដ្ឋារចនាសម្ព័ន្ធដែលបម្រើផ្ទាល់សម្រាប់ការដាំដុះកៅស៊ូ ដូចជា សំណង់អគារ (ការិយាល័យ អគារស្នាក់នៅរបស់កម្មករ សាលសហគមន៍ អាងឬឃ្លាំងបង្កកកៅស៊ូ ឬរោងម៉ាស៊ីន) ផ្លូវ ស្ពាន ស្រះ ឬអាងផ្ទុកកាកសំណល់

ឃ. ចំណាយទិញជីសម្រាប់ដាំដុះដំណាំកៅស៊ូ

ង. ចំណាយលើការជួលដី នៅក្នុងដំណាក់កាលឈូសឆាយ និងដាំដុះដើមកៅស៊ូ



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

ច. ចំណាយគ្រឿងចក្រដែលបានទិញក្នុងរយៈពេលឈូសឆាយ និងដាំដុះដើមកៅស៊ូ

ឆ. ចំណាយលើការប្រាក់ពីកម្ចីស្ថិតនៅក្នុងដំណាក់កាលឈូសឆាយ និងដាំដុះដើមកៅស៊ូ

ជ. ចំណាយផ្សេងៗដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការដាំដុះដើមកៅស៊ូ ក្នុងរយៈពេលឈូសឆាយ និងដាំដុះ។

២.២. ចំណាយដែលមានលក្ខណៈផ្ទុយពីចំណុច ២.១ ដែលបានរៀបរាប់ខាងលើ ត្រូវចាត់ជាចំណាយប្រតិបត្តិការ។ ចំណាយទាំងនោះរួមមាន÷

ក. ចំណាយក្នុងការដាំជំនួសចំពោះដំណាំខូច÷ គឺជាប្រភេទចំណាយណាដែលទាក់ទងផ្ទាល់ទៅនឹងការដាំដុះជំនួសវិញ ដោយរួមបញ្ចូលទាំងចំណាយផ្សេងៗសម្រាប់កែលម្អក្នុងចំការ ការដាក់បង្គោលការពារដំណាំដែលទើបនឹងជំនួសក្រោយរយៈពេលប្រមូលផល។ ផ្ទុយទៅវិញ ក្នុងករណីដាំដំណាំកៅស៊ូទាំងស្រុង ត្រូវអនុវត្តតាមចំណុច ២.១ ខាងលើ

ខ. ចំណាយលើសម្ភារបរិក្ខារ ដែលមិនពាក់ព័ន្ធនឹងការដាំដុះដំណាំកៅស៊ូ

គ. ចំណាយផ្សេងៗដែលមិនពាក់ព័ន្ធផ្ទាល់នឹងសកម្មភាពអាជីវកម្មដំណាំកៅស៊ូ។

## ៣. រំលស់អនុញ្ញាតតាមច្បាប់សារពើពន្ធ

ដំណាំកៅស៊ូ ត្រូវធ្វើរំលស់តាមវិធីរំលស់ដូចមានចែងក្នុងកថាខណ្ឌ ៤ ទ្រព្យសកម្មរយៈពេលវែង នៃប្រការ៣៨ នៃប្រកាសស្ដីពីពន្ធលើប្រាក់ចំណូល។ ដោយឡែក ចំពោះទ្រព្យសកម្មរយៈពេលវែងដទៃទៀត សហគ្រាសត្រូវអនុវត្តតាមវិធានរំលស់តាមច្បាប់ស្ដីពីសារពើពន្ធដូចមានចែងក្នុងផ្នែកទី ៣(មាត្រា ១៣ ថ្មី) នៃច្បាប់ស្ដីពីសារពើពន្ធ។

ក្នុងករណីដំណាំកៅស៊ូមានការចាប់ផ្ដើមដាំក្នុងពេលផ្សេងៗគ្នា សហគ្រាសត្រូវទទួលស្គាល់ថ្លៃដើមកៅស៊ូ និងត្រូវធ្វើរំលស់ផ្សេងៗគ្នាទៅតាមតំបន់នីមួយៗ។

**ឧទាហរណ៍**÷សហគ្រាស "ក" ដែលប្រកបអាជីវកម្មដាំដុះកៅស៊ូ មានប្រតិបត្តិការចំណាយពាក់ព័ន្ធនឹងការដាំដុះកៅស៊ូ ដូចខាងក្រោម÷

- ចំណាយលើការទិញកូនកៅស៊ូចំនួន ១០ ០០០ ០០០ រៀល
- ចំណាយលើការឈូសឆាយដីចំនួន ៥០ ០០០ ០០០ រៀល
- ចំណាយលើកម្លាំងកម្មករដាំដុះកូនកៅស៊ូចំនួន ៦០ ០០០ ០០០ រៀល
- ចំណាយដាំជំនួសចំពោះដំណាំខូច (ក្រោយរយៈពេលទទួលផល)ចំនួន ៥ ០០០ ០០០ រៀល
- ចំណាយលើការប្រាក់ខ្ចីពីធនាគារ ចំនួន ២០ ០០០ ០០០ រៀល (ក្នុងរយៈពេលដាំដុះ) និង ១០ ០០០ ០០០រៀល (ក្រោយរយៈពេលទទួលផល)

ដើម្បីគណនារំលស់ដើមកៅស៊ូសម្រាប់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ សហគ្រាស "ក" ត្រូវអនុវត្តដូចខាងក្រោម÷

**ក.** ចំណាយគិតចាប់ពីការបណ្ដុះពូជរហូតដល់ឆ្នាំដែលចាប់ផ្ដើមប្រមូលផលដែលត្រូវបញ្ចូលក្នុងថ្លៃដើមកៅស៊ូ សរុបចំនួន ១៤០ ០០០ ០០០ រៀល រួមមាន÷

- ចំណាយលើការប្រាក់ខ្ចីក្នុងរយៈពេលដាំដុះចំនួន ២០ ០០០ ០០០ រៀល
- ចំណាយលើការទិញកូនកៅស៊ូចំនួន ១០ ០០០ ០០០ រៀល
- ចំណាយលើការឈូសឆាយដីចំនួន ៥០ ០០០ ០០០ រៀល
- ចំណាយលើកម្លាំងកម្មករដាំដុះកូនកៅស៊ូចំនួន ៦០ ០០០ ០០០ រៀល

**ខ.** ចំណាយលើការដាំជំនួសចំពោះដំណាំខូចចំនួន ៥ ០០០ ០០០ រៀល និង ចំណាយលើការប្រាក់ខ្ចីពីធនាគារ ចំនួន ១០ ០០០ ០០០រៀល (ក្រោយរយៈពេលទទួលផល) ត្រូវបានចាត់ទុកជាចំណាយប្រតិបត្តិការ ឬត្រូវបានគិតបញ្ចូល ក្នុងរបាយការណ៍ចំណូល និងចំណាយប្រចាំឆ្នាំ។

**គ. តារាងគណនាចំណាយរំលស់របស់ដើមកៅស៊ូ÷**

សហគ្រាស ត្រូវធ្វើការគណនារំលស់ដើមកៅស៊ូតាមអត្រាសម្រាប់ឆ្នាំជាប់ពន្ធនីមួយៗដូចខាងក្រោម÷

| ឆ្នាំទទួលផល | អត្រារំលស់ | ចំណាយរំលស់ប្រចាំឆ្នាំ | ចំណាយរំលស់បង្គរ | សមតុល្យនៅសល់ |
|---|---|---|---|---|
| ឆ្នាំទី១ ដល់ទី២ | ៣% | ៤ ២០០ ០០០ | ៨ ៤០០ ០០០ | ១៣១ ៦០០ ០០០ |
| ឆ្នាំទី៣ ដល់ទី៤ | ៤% | ៥ ៦០០ ០០០ | ១៩ ៦០០ ០០០ | ១២០ ៤០០ ០០០ |
| ឆ្នាំទី៥ ដល់ទី១០ | ៥% | ៧ ០០០ ០០០ | ៦១ ៦០០ ០០០ | ៧៨ ៤០០ ០០០ |
| ឆ្នាំទី១១ ដល់ទី១២ | ៧% | ៩ ៨០០ ០០០ | ៨១ ២០០ ០០០ | ៥៨ ៨០០ ០០០ |
| ឆ្នាំទី១៣ ដល់ទី១៥ | ៦% | ៨ ៤០០ ០០០ | ១០៦ ៤០០ ០០០ | ៣៣ ៦០០ ០០០ |
| ឆ្នាំទី១៦ ដល់ទី១៩ | ៥% | ៧ ០០០ ០០០ | ១៣៤ ៤០០ ០០០ | ៥ ៦០០ ០០០ |
| ឆ្នាំទី២០ | សមតុល្យនៅសល់ | ៥ ៦០០ ០០០ | ១៤០ ០០០ ០០០ | ០ |

## ៤. ការកំណត់ថ្លៃដើមទិន្នផលដំណាំកៅស៊ូ

សហគ្រាសដែលប្រកបអាជីវកម្មដាំដុះដំណាំកៅស៊ូ ត្រូវកត់ត្រានូវចលនាស្តុកដើមគ្រា ស្តុកផលិតបានក្នុងគ្រា និងស្តុកចុងគ្រា ដោយត្រូវធ្វើការបែងចែក និងវាស់វែងប្រភេទទិន្នផលនីមួយៗដោយឡែកពីគ្នា។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថាគ្រប់សហគ្រាសដែលប្រកបអាជីវកម្មដាំដំណាំកៅស៊ូ ក្នុងព្រះរាជាណាចក្រកម្ពុជា នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយ ប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**